雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.202

# ប្រទេសចិន-ខេត្តយូនណាន

khmerlight@163.com
yunnangateway.com
Follow Amazing Yunnan on Facebook

រស្មីកម្ពុជា ប្រចាំថ្ងៃ

ឆ្នាំទី27 លេខ8083 ថ្ងៃសុក្រ ទី22 ខែវិច្ឆិកា ឆ្នាំ2019

## សហគ្រាសខេត្តយូនណាន ពួតដៃចូលរួមពិព័រណ៍នាំចូលចិន អន្តរជាតិទីផ្សារដែលបើកចំហបង្ហាញរឿងឈ្នះ-ឈ្នះដ៏ច្រើន

នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ ២០១៩ កម្មវិធីផ្សព្វផ្សាយពីកិច្ចសហប្រតិបត្តិការលើកម្រោងវិនិយោគ និងនាំចូលទំនិញរបស់សហគ្រាសសំខាន់ នៃខេត្តយូនណានបានរៀបចំឡើងក្នុងក្រុងសៀងហៃក្រោមប្រធានបទ "បើកចំហវេទិកាថ្មីសម្រេចសុបិនយូនណានថ្មី" ក្នុងឱកាសពិព័រណ៍នាំចូលចិនអន្តរជាតិលើកទី២ ។



បេតិកភណ្ឌវប្បធម៌ អរូបីខេត្តយូនណានត្រូវដាក់តាំង ពិព័រណ៍ក្នុងពិព័រណ៍នាំចូលចិនអន្តរជាតិ ។ លោក ហឺ ជឹងរិន អ្នកបន្ត វេនវប្បធម៌ តុងប៉ា ជនជាតិណាស៊ីកំពុងធ្វើបទបង្ហាញពីអក្សរតុងប៉ារបស់ ជនជាតិណាស៊ីចំពោះអ្នកទស្សនា

ក្នុងឱកាសនេះ ខេត្តយូនណានបានខិតខំយ៉ាងសកម្មដើម្បីចាត់វិធានការបើកចំហកែលម្អបរិយាកាសពាណិជ្ជកម្ម និងបង្ហាញសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការឈ្នះ-ឈ្នះ ។

នៅចុងខែសីហាឆ្នាំនេះ តំបន់ពិសោធន៍ពាណិជ្ជកម្មសេរីចិន(ខេត្តយូនណាន)បានត្រូវសម្ពោធស្លាកជាផ្លូវការ ។ ក្នុងពិព័រណ៍នាំចូលចិនអន្តរជាតិលើកនេះ តំបន់ពិសោធន៍ពាណិជ្ជកម្មសេរីចិន(ខេត្តយូនណាន)បានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំងពីសហគ្រាសផ្សេងៗ ។ លោក ចាវ យូយជូន ប្រធានមន្ទីរពាណិជ្ជកម្មខេត្តយូនណាន បានធ្វើបទឧទ្ទេសនាមអំពីគោលនយោបាយលើកទឹកចិត្តនិងទិសដៅអភិវឌ្ឍន៍នៃតំបន់ពិសោធន៍ពាណិជ្ជកម្មសេរីចិន(ខេត្តយូនណាន) ។ លោកបានបញ្ជាក់ថាខេត្តយូនណានសូមស្វាគមន៍វិនិយោគិននិងសហគ្រិននៃបណ្តាប្រទេសនានាមកក្តាប់ជាប់ឱកាសដ៏ល្អនេះប្រើឧត្តមភាពនៃតំបន់ពិសោធន៍ពាណិជ្ជកម្មសេរីចិន(ខេត្តយូនណាន) ដើម្បីធ្វើការច្នៃប្រឌិតថ្មីនិងបង្កើតមុខជំនួញថ្មី។ ខ្ញុំសង្ឃឹមថា ភ្ញៀវកិត្តិយសគ្រប់រូបអាចដើរតួនាទីជាស្ពាននិងចំណងតភ្ជាប់គ្នារួមសហការគ្នាជាមួយខេត្តយូនណានដើម្បី កសាងតំបន់ពិសោធន៍ពាណិជ្ជកម្មសេរីចិន(ខេត្តយូនណាន) ឱ្យបានកាន់តែល្អ ប្រសើរចែករំលែកគ្នាអំពីកាលានុវត្តភាពដែលនាំមកដោយការធ្វើកំណែ ទម្រង់និងបើកចំហ ព្រមទាំងចែក រំលែកគ្នាអំពីសមិទ្ធផលអភិវឌ្ឍន៍ដែលមានលក្ខណៈនវានុវត្តន៍។

សហគ្រិនដែលចូលរួមកម្មវិធីនេះ បានថ្លែងចំណាប់អារម្មណ៍ថា កម្មវិធីថ្ងៃនេះបានបើកច្រកមួយឱ្យសហគ្រាសយើងដែលជាច្រកសំខាន់មួយសម្រាប់ស្គាល់កាន់តែច្បាស់នូវខេត្តយូនណាន ។ យើងបានទទួលអារម្មណ៍ថា ខេត្តយូនណានមានបរិយាកាសពាណិជ្ជកម្មយ៉ាងល្អប្រសើរហើយបានផ្តល់សេវាកម្មរដ្ឋបាលកម្រិតខ្ពស់។ មុខងារនៃតំបន់ពិសោធន៍ពាណិជ្ជកម្មសេរីចិន(ខេត្តយូនណាន)មានពាក់ព័ន្ធជិតស្និទ្ធទៅនឹងអាជីវកម្មរបស់យើង យើងក៏សង្ឃឹមថា នឹងអាចចូលធ្វើអាជីវកម្មក្នុងតំបន់នេះដែរ ។ នេះគឺជាសំឡេងរួមរបស់សហគ្រាសចិននិងបរទេស ។

ក្នុងឱកាសពិព័រណ៍នាំចូលចិនអន្តរជាតិសហគ្រាសខេត្តយូនណានបានបង្កើតភាពជាដៃគូជាមួយមិត្តភក្តិកាន់តែច្រើននិងបានទទួលផលប្រយោជន៍ជាក់ស្តែង ។ ក្នុងតំបន់ពិព័រណ៍បរិក្ខារសុខាភិបាលនិងថ្នាំ ឱសថនៃពិព័រណ៍នាំចូលចិនអន្តរជាតិលើកនេះ តំណាងប្រព័ន្ធសុខាភិបាលខេត្តយូនណានប៉ុន្មានរូបបានចូលរួមទស្សនាពិព័រណ៍ និងបានទទួលសមិទ្ធផលច្រើន ។ ក្នុងពិព័រណនាំចូលចិនអន្តរជាតិនេះ មន្ទីរពេទ្យខេត្តយូនណានជាច្រើនបានបង្កើតកិច្ចសហប្រតិបត្តិការជាមួយសហគ្រាសដែលចូលរួមការតាំងពិព័រណ៍។ក្រុមហ៊ុនសុខាភិបាលវ៉ាលីអានជាក្រុមហ៊ុនមួយដែលបានចុះកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការជាមួយមន្ទីរពេទ្យព្យាបាលជំងឺពកខេត្តយូនណាន។ លោកស្រី ឆាវ សាន តំណាងក្រុមហ៊ុនវ៉ាលីអាន បានគូសបញ្ជាក់ថា ខេត្តយូនណានមានឧត្តមភាពសម្រាប់ជំរុញការអភិវឌ្ឍតំបន់អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ ។ ក្រោមបរិការណ៍នៃការកសាង"ខ្សែក្រវាត់មួយ និងផ្លូវមួយ"ខេត្តយូនណានមានសក្តានុពលធំធេងក្នុងការជំរុញការលើកកម្ពស់កម្រិតថ្នាក់ផ្នែកសុខាភិបាលក្នុងតំបន់តាមរយៈការអភិវឌ្ឍប្រព័ន្ធសុខាភិបាលរបស់ខ្លួន ។ លោក ហ្វាងយូនឆាវប្រធានមន្ទីរពេទ្យព្យាបាលជំងឺពកខេត្តយូនណានប្រធានមន្ទីរពេទ្យលេខ៣នៃសាកលវិទ្យាល័យវេជ្ជសាស្ត្រក្រុងគុនមីងនិងជាប្រធានមជ្ឈមណ្ឌលព្យាបាលជំងឺមហារីកខេត្តយូនណានបានឯកភាពគ្នាលើគំនិតទស្សនៈរបស់លោកស្រីឆាវ សាន ។ លោកបានបន្ថែមថាពិព័រណ៍នាំចូលចិនអន្តរជាតិក៏ជាវេទិកាផ្លាស់ប្តូរអំពីព័ត៌មានដែរ។ នៅទីនេះខេត្តយូនណានធ្វើការផ្លាស់ប្តូរគ្នាជាមួយបណ្តាប្រទេសនានាសិក្សារៀនសូត្រពីគ្នា និងបំពេញបន្ថែមគ្នាទៅវិញទៅមក ៕

**ដោយ លីវជឺយូ ហាន ឈីង យាន់ និង លីសាវម៉េង**

## ពិព័រណ៍នាំចូលចិនអន្តរជាតិធ្វើឱ្យ យើងទាំងអស់គ្នាដើរកាន់តែខិតជិតនឹងគ្នា

លោក សំ វិបុល ប្រធានការិយាល័យសម្របសម្រួលអ្នកកាសែតជាតិនិងអន្តរជាតិនាយកដ្ឋានមណ្ឌលព័ត៌មាននៃអគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ក្រសួងព័ត៌មានកម្ពុជា បានបញ្ជាក់ថា ឯកឧត្តម ស៊ីជីនភីងមានប្រសាសន៍ក្នុងពិធីបើកពិព័រណ៍នាំចូលចិនអន្តរជាតិលើកទី២ នេះថា "ប្រទេសចិនមានទីផ្សារធំណាស់សូមស្វាគមន៍មិត្តទាំងអស់គ្នាមកមើលម្តង ។" ខ្ញុំជឿជាក់ថា បងប្អូនខ្មែរជាច្រើនបានទទួលការអញ្ជើញនេះពីឯកឧត្តមស៊ី ជីនភីងតាមប្រព័ន្ធផ្សព្វផ្សាយនៃប្រទេសកម្ពុជាហើយ។

ឆ្នាំនេះគណៈប្រតិភូកម្ពុជាបាននាំយកអង្ករក្រអូបខ្មែរដ៏ឆ្ងាញ់ទៅចូលរួមពិព័រណ៍នាំចូលចិនអន្តរជាតិលើកទី២ ។ ប៉ុន្មានខែមុន លោក សំវិបុល ធ្លាប់ឃើញព័ត៌មានតាមកាសែតខេត្តយូនណានថា អង្ករផ្កាម្លិះខ្មែរបានត្រូវនាំយកទៅដាក់លើតុបាយរបស់ប្រជាជននៅខេត្តយូនណាននិងបានទទួលការកោតសរសើរនិងការវាយតម្លៃខ្ពស់ណាស់ ។ ប្រទេសចិនជាទីផ្សារនាំចេញអង្ករសំខាន់មួយរបស់ប្រទេសកម្ពុជា ។ ខ្ញុំសង្ឃឹមថា ក្លិនក្រអូបនៃអង្ករខ្មែរនឹងអាចសាយភាយលើពិភពលោកទាំងមូលក្នុងពេលឆាប់ៗតាមរយៈការចូលរួមពិព័រណ៍នាំចូលចិនអន្តជាតិដែលជាច្រកដ៏សំខាន់និងធំ ។

នៅឆ្នាំទៅ កម្ពុជាបានចូលរួមពិព័រណ៍នាំចូលចិនអន្តរជាតិលើកទី១ ។ ឆ្នាំនេះកម្ពុជា បានចូលរួមពិព័រណ៍នាំចូលចិនអន្តរជាតិ ដើម្បីបង្ហាញពីរចនាបថ ពិសេសរបស់ខ្លួនចំពោះដៃគូចិននិងប្រទេសផ្សេងៗទៀតក្នុងនាមជាប្រទេសកិត្តិយសនៃពិព័រណ៍នេះ ។ ពិព័រណ៍នាំចូលចិនអន្តរជាតិដែលជាឆាកសម្តែងអន្តរជាតិដ៏ធំនេះបានជួយបង្កើនទំនាក់ទំនងនិងការយល់ដឹងគ្នាទៅវិញទៅមករវាងបណ្តាប្រទេសនានាដែលចូលរួមការតាំងពិព័រណ៍ ហើយបានផ្តល់ឱកាសកាន់តែច្រើនក្នុងការបង្កើនការផ្លាស់ប្តូរគ្នានិងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្នា ។

លោកបានបញ្ជាក់ទៀតថា កម្ពុជាជាអរិយប្រទេសបុរាណមួយដែលមានប្រវត្តិសាស្ត្រដ៏យូរលង់និងវប្បធម៌ដ៏ក្រាស់ក្រែល ។ ខ្ញុំជឿជាក់ថា នឹងអាចមានប្រទេសកាន់តែច្រើនយល់ដឹងអំពីប្រទេសកម្ពុជា ហើយនឹងមានមនុស្សកាន់តែច្រើនមានបំណងចង់ទៅធ្វើវិនិយោគនៅកម្ពុជា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម អប់រំ និងវប្បធម៌ជាដើម ព្រមទាំងពង្រឹងចំណងមិត្តភាពជាមួយប្រទេសកម្ពុជា។ ខ្ញុំគិតថា ពិព័រណ៍នាំចូលចិនអន្តរជាតិជាឱកាសណាត់ជួបគ្នាដ៏ល្អប្រសើរដែលនឹងអាចធ្វើឱ្យបណ្តាប្រទេសនានាដើរកាន់តែខិតជិតនឹងគ្នា៕

**(កាសែតយូនណានដេលី)**

## ឯកឧត្តមស៊ី ជីនភីង បកស្រាយ ពីការបន្តជំរុញការបើកចំហទីផ្សារ

ប្រទេសចិនរៀបចំពិព័រណ៍នាំចូលចិនអន្តរជាតិពង្រីកទំហំនៃការនាំចូលទំនិញដោយមានភាពម្ចាស់ការ គឺដើម្បីជំរុញការបើកចំហរដោយមានកម្រិតខ្ពស់ចំពោះបរទេសក្នុងដំណាក់កាលថ្មី ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការរួមគ្នាកសាង"ខ្សែក្រវាត់មួយនិងផ្លូវមួយ" រួមចំណែកយ៉ាងសកម្មក្នុងការរួមសហការគ្នាដើម្បីកសាងសេដ្ឋកិច្ចពិភពលោកដែលមានលក្ខណៈបើកចំហរ។ ផលិតផលពាណិជ្ជកម្មនៃពិព័រណ៍នាំចូលចិនអន្តរជាតិគឺទំនិញនិងសេវាកម្មចំណែកកម្មវត្ថុនៃការផ្លាស់ប្តូរគ្នាគឺវប្បធម៌ និងទស្សនៈ ។ ប្រទេសចិនស្វាគមន៍ភ្ញៀវ ដែលមកពីគ្រប់ទិសទៅលើពិភពលោកគិតគូរពិចារណាអំពីផលប្រយោជន៍រួម របស់ពិភពលោកទាំងមូល និងសម្រប ទៅនឹងក្តីបំណងអំពីជីវភាពរស់នៅល្អប្រវររបស់ប្រជាជននៃបណ្តាប្រទេសនានា ៕

**(ដកស្រង់ចេញពីសុន្ទរកថារបស់ឯកឧត្តមស៊ី ជីនភីងដែលថ្លែងក្នុងពិធីបើកពិព័រណ៍នាំចូលចិនអន្តរជាតិលើកទី២)**

## វគ្គបណ្តុះបណ្តាលមន្ត្រីរាជការ និងអ្នកសារព័ត៌មាន ប្រទេសទន្លេឡានឆាង-មេគង្គលើកទី៤បើកវគ្គជាផ្លូវការ



មន្ត្រីរាជការ និង អ្នកសារព័ត៌មាន ១៦ រូប ដែលមកពី ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម ទៅទស្សនាផ្សារផ្កា ទូវណាន ក្រុង គុនមីង

កាលពីថ្ងៃទី១៤ ដល់ទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ វគ្គបណ្តុះបណ្តាលមន្ត្រីរាជការនិងអ្នកសារព័ត៌មានប្រទេសទន្លេឡានឆាង-មេគង្គលើកទី៤ បានរៀបចំជាផ្លូវការនៅក្រុងគុនមីងនៃខេត្តយូនណាន។

ក្រោមការគាំទ្រពីសាលារដ្ឋបាលប្រជាជនខេត្តយូនណាន និងការណែនាំពីផ្នែកឃោសនាការនៃគណៈកម្មាធិការបក្សកុម្មុយនីស្តចិនខេត្តយូនណាន ក្រុមហ៊ុនកាសែតយូនណានដេលីគ្រុប បានរៀបចំវគ្គបណ្តុះបណ្តាលនេះ ក្រោមប្រធានបទ "ឈ្វេងយល់អំពីប្រទេសចិនថ្មី"។ មន្ត្រីរាជការនិងអ្នកសារព័ត៌មាន១៦រូប ដែលមកពីប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម បានចូលរួមកម្មវិធីសិក្សានិងផ្លាស់ប្តូរគ្នាក្នុងក្រុងគុនមីង និងមណ្ឌលស្វយ័តជនជាតិហានី និងយី ហុងហឺ ។ ក្រៅពីនេះ មន្ត្រីរាជការនិងអ្នកសារព័ត៌មាននៃប្រទេសផ្សេងៗបានចូលរួមវេទិកាក្រុងពីរចិន-មីយ៉ាន់ម៉ា ឆ្នាំ២០១៩ និងកម្មវិធីសិក្សានិងទស្សនកិច្ចផ្សេងៗ ដើម្បីលើកសំណើ និងរួមចំណែកក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកសារព័ត៌មានជំរុញការតភ្ជាប់ក្រអៅបេះដូងរវាងប្រជាជននៃប្រទេសទន្លេឡានឆាង-មេគង្គ និងធ្វើឱ្យប្រព័ន្ធផ្សព្វផ្សាយដើរតួនាទីជាស្ពានមិត្តភាព។

លោក កែវ ច័ន្ទតារា ទីប្រឹក្សាក្រសួងព័ត៌មាននិងជាអគ្គនាយករងនៃអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជាបានអញ្ជើញចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ។ លោកបានមានប្រសាសន៍ថា កិច្ចសហប្រតិបត្តិការរវាងប្រព័ន្ធផ្សព្វផ្សាយប្រទេសផ្សេងៗកំពុងដើរតួនាទីកាន់តែសំខាន់ឡើងៗ។ វគ្គបណ្តុះបណ្តាលនេះបានផ្តល់វេទិកាសំខាន់មួយសម្រាប់បង្កើនការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការរវាងប្រទេសចិន និងប្រទេសទន្លេមេគង្គផ្សេងៗ។ ខ្ញុំជឿជាក់ថា មន្ត្រីរាជការនិងអ្នកសារព័ត៌មាននៃប្រទេសទន្លេមេគង្គអាចទទួលបានចំណេះដឹងច្រើន និងធ្វើការផ្លាស់ប្តូរគ្នាយ៉ាងស៊ីជម្រៅក្នុងវគ្គបណ្តុះបណ្តាលនេះហើយនឹងអាចមានការយល់ដឹងកាន់តែច្បាស់និងកាន់តែស៊ីជម្រៅអំពីប្រទេសចិន៕ **ដោយលីវជឺយូ**

## ការប្រកួតក្បាច់គុនប្រពៃណីប្រព័ន្ធសារព័ត៌មានប្រារព្ធនៅក្រុងគុនមីង

កាលពីថ្ងៃទី១៥ ដល់ទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ការប្រកួតក្បាច់គុនប្រពៃណីប្រព័ន្ធសារព័ត៌មាន "ខេត្តយូនណានដ៏ចម្រុះពណ៌ខ្សែក្រវាត់មួយនិងផ្លូវមួយ" បានប្រារព្ធនៅក្រុងគុនមីងនៃខេត្តយូនណាន។ បេក្ខជនបេក្ខនារី ៣០០នាក់ ដែលមកពីខេត្តចំនួន៩នៃប្រទេសចិនបានចូលរួមក្នុងការប្រកួតនេះ។ ក្នុងនោះមានក្រុមនិស្សិតបរទេសដែលបន្តការសិក្សានៅប្រទេសចិនចំនួន៥ក្រុម ។ ការប្រកួតនេះជាការប្រកួតក្បាច់គុនទី១ ដែលរៀបចំក្រោមប្រធានបទ "ខ្សែក្រវាត់មួយនិងផ្លូវមួយ" ហើយបានអនុញ្ញាតឱ្យនិស្សិតបរទេសដែលបន្តការសិក្សានៅខេត្តយូនណានចុះឈ្មោះចូលរួមការប្រកួតដើម្បីទាក់ទាញឱ្យនិស្សិតបរទេសកាន់តែច្រើនយកចិត្តទុកដាក់ដល់ក្បាច់គុនប្រពៃណីនិងជំរុញឱ្យវប្បធម៌ក្បាច់គុនចិនដើរឆ្ពោះទៅកាន់ពិភពលោក៕

**(កាសែតយូនណានដេលី)**



និស្សិតបរទេសនៅខេត្តយូនណានកំពុងហាត់ក្បាច់គុន